ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១១៣៥ ......សហវ.ប្រក

## ប្រកាស

## ស្តីពី

## ការចុះបញ្ជីពន្ធដារ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៤អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីអាករលើតម្លៃបន្ថែម
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានពន្ធដារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ១.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់វិធាននិងនីតិវិធីនៃការចុះបញ្ជីពន្ធដារ ដោយអនុលោមតាមមាត្រា ១០១ នៃច្បាប់ស្ដីពីសារពើពន្ធ។

**ប្រការ២.- គោលបំណង**

ប្រកាសនេះមានគោលបំណងដូចខាងក្រោម÷

- ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពន្ធដារ ដើម្បីគ្រប់គ្រងទិន្នន័យសហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬបុគ្គលទាំងឡាយ ឱ្យបានកាន់តែប្រសើរឡើង
- ពង្រឹងការផ្ដល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែមានលក្ខណៈល្អប្រសើរ
- ពង្រឹងការគាំទ្រដល់ការគ្រប់គ្រងការដាក់លិខិតប្រកាស ការធ្វើសវនកម្ម និងការប្រមូលបំណុលពន្ធ ឱ្យកាន់តែមានតម្លាភាព និងប្រសិទ្ធភាព។

**ប្រការ៣.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តការចុះបញ្ជីពន្ធដារ ចំពោះនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬបុគ្គលទាំងឡាយ ដែលមានសកម្មភាពសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះបច្ចេកសព្ទត្រូវបានកំណត់និយមន័យដូចតទៅ÷

- "ការចុះបញ្ជីពន្ធដារ" សំដៅដល់ការចុះបញ្ជីតាមរបបពិត (ស្វ័យប្រកាស) និងរបបម៉ៅការ នៅរដ្ឋបាលសារពើពន្ធចំពោះបុគ្គលទាំងឡាយណាដែលមានសកម្មភាពសេដ្ឋកិច្ច នៅព្រះរាជាណាចក្រកម្ពុជា។
- "សកម្មភាពសេដ្ឋកិច្ច" សំដៅដល់សកម្មភាពរបស់បុគ្គលដែលធ្វើអាជីវកម្ម ឬសកម្មភាព ជានិច្ចកាលជាប់បន្ត ឬមួយដងមួយគ្រា ដើម្បីរក ឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញ ឬសេវាដល់បុគ្គលដទៃ ក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។

**ប្រការ៥.- កាតព្វកិច្ចនៃការចុះបញ្ជីពន្ធដារ**

សហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬបុគ្គលទាំងឡាយ ត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីចាប់ផ្ដើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ឬក្រសួង ស្ថាប័នពាក់ព័ន្ធ។

សហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬបុគ្គលទាំងឡាយ ត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីការផ្លាស់ប្ដូរ អាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស ឬការផ្ទេរ។

ចំពោះការបញ្ឈប់ ឬបិទសកម្មភាពអាជីវកម្ម សហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬ

*Ik*.

បុគ្គលទាំងឡាយ ត្រូវដាក់ពាក្យស្នើសុំជម្រះបញ្ជីមករដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីរដ្ឋបាលសារពើពន្ធធ្វើសវនកម្ម មុននឹងចេញលិខិតបញ្ជាក់ស្ថានភាពសារពើពន្ធជូនជាផ្លូវការ។

**ប្រការ៦.- ការស្នើសុំចុះបញ្ជីពន្ធដារ**

សហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬបុគ្គលទាំងឡាយ ដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារត្រូវធ្វើការស្នើសុំចុះបញ្ជីដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ ឬតាមប្រព័ន្ធអេឡិកត្រូនិក ( E-registration ) ដែលមាននៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ។

ការស្នើសុំចុះបញ្ជីពន្ធដារត្រូវបង់ថ្លៃសេវាចុះបញ្ជី ចេញវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ ក្នុងតម្លៃ ៤០០.០០០ រៀល (បួនរយពាន់រៀល ) សម្រាប់អ្នកជាប់ពន្ធតាមរបបពិត (ស្វ័យប្រកាស )។ សម្រាប់ការចុះបញ្ជីពន្ធដារតាមរបបម៉ៅការ ត្រូវបង់ថ្លៃសេវាចុះបញ្ជី និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ ក្នុងតម្លៃ ២០.០០០ រៀល (ម្ភៃពាន់រៀល )។

**ប្រការ៧.- រយៈពេលនៃការចុះបញ្ជីពន្ធដារ**

- ចំពោះការចុះបញ្ជីតាមរយៈប្រព័ន្ធអេឡិកត្រូនិក ( E-registration ) ក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ អាចនឹងចំណាយរយៈពេលពី ១ថ្ងៃ ទៅ ៧ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងការចេញវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារដោយរដ្ឋបាលសារពើពន្ធ។
- ចំពោះការចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ តាមរយៈការបំពេញពាក្យស្នើសុំចុះបញ្ជីពន្ធដារអាចនឹងចំណាយរយៈពេលពី ៧ថ្ងៃ ទៅ ១០ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងការចេញវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ ដោយរដ្ឋបាលសារពើពន្ធ សម្រាប់ផ្តល់ភាពងាយស្រួលក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ។

**ប្រការ៨.- លក្ខខណ្ឌនៃការចុះបញ្ជីពន្ធដារ**

- **ការចុះបញ្ជីតាមរបបពិត (របបស្វ័យប្រកាស)**

ក្នុងការស្នើសុំចុះបញ្ជីពន្ធដារតាមរបបពិត (ស្វ័យប្រកាស) ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ឬប្រធានអង្គការ ត្រូវមកថតរូប ស្កែន (Scan) ម្រាមដៃផ្ទាល់នៅរដ្ឋបាលសារពើពន្ធ និងត្រូវបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ហើយភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ដើម្បីឱ្យមន្ត្រីពន្ធដារទទួលបន្ទុកបញ្ជាក់ពីការថតចម្លងចេញពីច្បាប់ដើម ឬច្បាប់ថតចម្លងដែលមានបញ្ជាក់ពីក្រសួង ស្ថាប័នសាមី ដូចខាងក្រោម÷

ក. ចំពោះ សហគ្រាសឯកបុគ្គល និងសហគ្រាសនីតិបុគ្គល

១. ឯកសារចុះបញ្ជីចេញដោយក្រសួងពាណិជ្ជកម្ម ឬក្រសួង ស្ថាប័នពាក់ព័ន្ធ

- លិខិតបញ្ជាក់ការចុះបញ្ជីនៃក្រសួងពាណិជ្ជកម្ម ឬក្រសួង ស្ថាប័នពាក់ព័ន្ធ
- លក្ខន្តិកៈក្រុមហ៊ុន សម្រាប់នីតិបុគ្គល
- លិខិតបញ្ជាក់ការតម្កល់ដើមទុនចុះបញ្ជីនៅធនាគារ។

២. ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករឬម្ចាស់ភាគហ៊ុន និងបណ្ណាធិការ

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ៣ខែ ដែលមានទំហំ ៣៥ × ៤៥ មីលីម៉ែត្រ ចំនួន ១សន្លឹក របស់អភិបាល ម្ចាស់ភាគហ៊ុន បណ្ណាធិការ អ្នកតំណាង ដែលមានការបញ្ជាក់ឈ្មោះម្ចាស់រូបថត និងចុះហត្ថលេខាទទួលខុសត្រូវដោយប្រធានក្រុមប្រឹក្សាភិបាល។

៣. ឯកសារបញ្ជាក់ទីតាំងទីចាត់ការសហគ្រាស អាជីវកម្មគោលដើម សាខាសហគ្រាស និងឃ្លាំង

- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ។

៤. ឯកសារផ្សេងៗ

- វិញ្ញាបនបត្រចុះបញ្ជីរបស់គណៈកម្មាធិការវិនិយោគកម្ពុជា ឬគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត (សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់)
- អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)។

**ខ. ចំពោះអង្គការនានា**

១. លិខិតអនុញ្ញាតចេញដោយ ក្រសួង ស្ថាប័ន មានសមត្ថកិច្ច

២. លក្ខន្តិកៈ ឬអនុស្សរណៈយោគយល់គ្នា ជាមួយក្រសួង ស្ថាប័ន មានសមត្ថកិច្ច

៣. ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ប្រធានអង្គការ

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ការស្នាក់នៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

៤. ឯកសារបញ្ជាក់ទីតាំងអង្គការ

- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងការិយាល័យ
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ។

• **ការចុះបញ្ជីតាមរបបម៉ៅការ**

ក្នុងការស្នើសុំចុះបញ្ជីពន្ធដារតាមរបបម៉ៅការ ម្ចាស់អាជីវកម្មដ្ឋាន ត្រូវបំពេញព័ត៌មានក្នុងទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ ហើយភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ដើម្បីឱ្យមន្ត្រីពន្ធដារទទួលបន្ទុកបញ្ជាក់ពីការថតចម្លងចេញពីច្បាប់ដើម ឬច្បាប់ថតចម្លងដែលមានបញ្ជាក់ពីក្រសួង ស្ថាប័នសាមី ឬស្ថាប័នមានសមត្ថកិច្ច ដូចខាងក្រោម÷

១. លិខិតអនុញ្ញាតចេញដោយ ក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)

២. អាជ្ញាប័ណ្ណដែលចេញដោយក្រសួង ស្ថាប័ន មានសមត្ថកិច្ច (បើមាន)

៣. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

៤. ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំង

៥. លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ (បើមាន)

៦. រូបថតបច្ចុប្បន្នមិនលើសពីរយៈពេល ៣ខែ ដែលមានទំហំ ៣៥ × ៤៥ មីលីម៉ែត្រ ចំនួន ២សន្លឹក ដោយមានការសរសេរឈ្មោះ និងចុះហត្ថលេខាលើខ្នងរូបថត។

**ប្រការ៩.- ការស្នើសុំបញ្ជាក់សាខាសហគ្រាស**

សហគ្រាសដែលបានចុះបញ្ជីពន្ធដារនៅរដ្ឋបាលសារពើពន្ធ ហើយបានបង្កើតសាខារបស់ខ្លួន ត្រូវដាក់ពាក្យស្នើសុំលិខិតបញ្ជាក់សាខាសហគ្រាសដោយផ្ទាល់ នៅរដ្ឋបាលសារពើពន្ធដោយផ្ទាល់តាមរយៈការបំពេញពាក្យស្នើសុំលិខិតបញ្ជាក់សាខា ឬតាមប្រព័ន្ធអេឡិចត្រូនិក (E-registration) ក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ។ ចំពោះរយៈពេលនៃការបញ្ជាក់សាខាគឺដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ។

រាល់ការស្នើសុំបញ្ជាក់សាខាសហគ្រាស ត្រូវភ្ជាប់មកជាមួយនូវឯកសារច្បាប់ដើម ដើម្បីឱ្យមន្ត្រីពន្ធដារទទួលបន្ទុកបញ្ជាក់ពីការថតចម្លងចេញពីច្បាប់ដើម ឬច្បាប់ថតចម្លងដែលមានបញ្ជាក់ពីក្រសួង ស្ថាប័នសាមី ដូចខាងក្រោម÷

១. លិខិតទទួលចុះបញ្ជីនូវការបង្កើតសាខាសហគ្រាស របស់ក្រសួងពាណិជ្ជកម្ម ឬក្រសួងស្ថាប័នពាក់ព័ន្ធ

២. ឯកសារបញ្ជាក់ទីតាំងសហគ្រាស

- ប័ណ្ណកម្មសិទ្ធិកាន់កាប់ទីតាំង ឬកិច្ចសន្យាជួលទីតាំងប្រកបអាជីវកម្ម
- លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធអចលនទ្រព្យ ឬព័ត៌មានអចលនទ្រព្យ។

**ប្រការ១០.- ការបញ្ជាក់ការទទួលសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ**

រដ្ឋបាលសារពើពន្ធ ត្រូវចេញលិខិតបញ្ជាក់ការទទួលសំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារ ដោយបញ្ជាក់កាលបរិច្ឆេទទទួលសំណុំឯកសារបន្ទាប់ពីបានពិនិត្យឃើញថា សំណុំឯកសារស្នើសុំចុះបញ្ជីពន្ធដារនោះត្រឹមត្រូវ និងគ្រប់គ្រាន់តាមការកំណត់ក្នុងប្រការ៨ ឬប្រការ៩ នៃប្រកាសនេះ។

**ប្រការ១១.- សិទ្ធិរបស់រដ្ឋបាលសារពើពន្ធក្នុងការចុះបញ្ជីអ្នកជាប់ពន្ធ**

អនុលោមតាមមាត្រា ១០៣ នៃច្បាប់ស្តីពីសារពើពន្ធ រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជី ចំពោះសហគ្រាសនីតិបុគ្គល ឬក្រុមអាជីវកម្ម ឬសហគ្រាសឯកបុគ្គល ឬបុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជី តែពុំបានមកចុះបញ្ជី ក្នុងករណីនេះរដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី។

**ប្រការ១២.- សិទ្ធិរបស់រដ្ឋបាលសារពើពន្ធក្នុងការបដិសេធការចុះបញ្ជីពន្ធដារ**

រដ្ឋបាលសារពើពន្ធមានសិទ្ធិបដិសេធការចុះបញ្ជីពន្ធដារ ចំពោះសហគ្រាសដែល ប្រធានក្រុមប្រឹក្សាភិបាល អភិបាល កម្មសិទ្ធិករឬម្ចាស់ភាគហ៊ុន និងអ្នកតំណាង មានជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងសហគ្រាសដទៃដែលមានជំពាក់បំណុលពន្ធ។ រដ្ឋបាលសារពើពន្ធអាចចុះបញ្ជីបាន លុះត្រាតែមានការទូទាត់បំណុលពន្ធជាមុនសិន ឬមានកិច្ចសន្យាធានាសងបំណុលពន្ធ។

**ប្រការ១៣.- សិទ្ធិរបស់អ្នកជាប់ពន្ធក្នុងការតវ៉ាសេចក្តីសម្រេចរដ្ឋបាលសារពើពន្ធ**

ក្នុងករណីរដ្ឋបាលសារពើពន្ធបដិសេធការចុះបញ្ជី អ្នកជាប់ពន្ធមានសិទ្ធិដាក់បណ្តឹងតវ៉ាទៅអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីធ្វើការពិនិត្យឡើងវិញនូវការសម្រេចកន្លងមក។ ក្នុងករណីអ្នកជាប់ពន្ធមិនយល់ព្រមលើសេចក្តីសម្រេចរបស់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អ្នកជាប់ពន្ធអាចប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១៤.- ការធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់សហគ្រាសដែលបានចុះបញ្ជី**

ចំពោះសហគ្រាសដែលបានចុះបញ្ជីពន្ធដារមុនថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៤ ប្រធានក្រុមប្រឹក្សាភិបាល ឬម្ចាស់សហគ្រាស ត្រូវមកធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដាររបស់ខ្លួនតាមការជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ។ បន្ទាប់ពីបានធ្វើបច្ចុប្បន្នភាពនៃការចុះបញ្ជីពន្ធដាររួច រដ្ឋបាលសារពើពន្ធត្រូវចេញវិញ្ញាបនបត្រចុះបញ្ជីពន្ធដារថ្មី និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ។

ការធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់សហគ្រាសដែលបានចុះបញ្ជីពន្ធដារ ត្រូវបង់ថ្លៃសេវាចេញវិញ្ញាបនបត្រចុះបញ្ជីពន្ធដារថ្មី និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ នៅរដ្ឋបាលសារពើពន្ធ ក្នុងតម្លៃ ២០០.០០០ រៀល (ពីររយពាន់រៀល) សម្រាប់អ្នកជាប់ពន្ធតាមរបបពិត (ស្វ័យប្រកាស )។ សម្រាប់ការចុះបញ្ជីពន្ធដារតាមរបបម៉ៅការ ត្រូវបង់ថ្លៃសេវាចុះបញ្ជី និងប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ នៅរដ្ឋបាលសារពើពន្ធ ក្នុងតម្លៃ ១០.០០០ រៀល(ដប់ពាន់រៀល)។

**ប្រការ១៥.- ទោសទណ្ឌ**

ការមិនបានចុះបញ្ជីពន្ធដារ ឬការមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរក្នុងការចុះបញ្ជី ត្រូវរងទោសទណ្ឌតាមច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ១៦.- និរាករណ៍**

ប្រកាសលេខ ១០០៤ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការកែប្រែបំពេញបន្ថែមឯកសារក្នុងទម្រង់បែបបទសម្រាប់ការចុះបញ្ជីពន្ធដារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៧.- ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ តុលា ឆ្នាំ២០១៤

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ១៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ